# វៀតណាម

មជ្ឈមណ្ឌលសម្រាប់ការវិភាគ និងព្យាករណ៍ (CAF) នៃបណ្ឌិត្យសភាវិទ្យាសាស្ត្រសង្គមវៀតណាមបានធ្វើការស្ទង់មតិតាមទូរស័ព្ទជាមួយនឹង ៩៩៨ គ្រួសារ ដែលមានសមាជិកយ៉ាងហោចណាស់ ១ នាក់ ធ្វើការនៅក្នុងឧស្សាហកម្មកាត់ដេរ ឬបដិសណ្ឋារកិច្ច។ និយោជិតខ្លះ ត្រូវសម្រាកពីការងារ ឯខ្លះទៀតត្រូវធ្វើការកាត់បន្ថយម៉ោង។ ករណីនេះ បានកាត់បន្ថយប្រាក់ចំណូលយ៉ាងខ្លាំងនៅកំឡុងពាក់កណ្តាលឆ្នាំ២០២១។ ប៉ុន្តែអ្នកចូលរួមស្ទង់មតិភាគច្រើនបានរាយការណ៍ថានៅពាក់កណ្តាលឆ្នាំ២០២២ ឱកាសការងារមានការស្តារឡើងវិញគួរឱ្យកត់សម្គាល់។

ផលប៉ះពាល់លើនិយោជិត ក្នុងឧស្សាហកម្មបដិសណ្ឋារកិច្ចមានភាពខ្លាំងក្លា ជាងនិយោជិតក្នុងឧស្សាហកម្មកាត់ដេរ។ គ្រួសារដែលមានស្ត្រីជាមេគ្រួសារ បានជួបប្រទះការស្តារឡើងវិញខ្សោយជាងគ្រួសារដែលមានបុរសជាមេគ្រួសារ។

> **បន្ទុកនៃការថែទាំ និងការងារផ្ទះ បានធ្លាក់លើស្ត្រី ប៉ុន្តែបុរសកាន់តែច្រើនទទួលបានការគាំទ្រជាងស្ត្រីសម្រាប់គ្រួសាររបស់ពួកគេ។**

ការបញ្ឈប់ការងារជាអចិន្ត្រៃយ៍ មានកម្រិតទាបជាងការរំពឹងទុកក្នុងឆ្នាំ២០២១។ ៨៦.៨% នៃអ្នកធ្វើការក្នុងឧស្សាហកម្មកាត់ដេរយល់ថា ផលប៉ះពាល់នៃជំងឺរាតត្បាត នឹងកន្លងផុតទៅក្នុងពេលឆាប់ៗនេះ។ ទោះជាយ៉ាងណាក៏ដោយ នៅឆ្នាំ២០២២ ការរំពឹងទុកនេះបានថយចុះដល់ ៤៨.៩% ។

នៅឆ្នាំ២០២១ មាន ៣១.៦% នៃនិយោជិតយល់ថា ពួកគេមិនអាចផ្លាស់ប្តូរទៅធ្វើមុខរបរផ្សេងទៀតបាន ដោយសារតែពួកគេខ្វះខាតជំនាញ ហើយអ្នកខ្លះទៀតយល់ថា រង់ចាំឲ្យជំងឺរាតត្បាតផុតរលត់សិន។ នៅឆ្នាំ២០២២ ៤៥.៦% នៃនិយោជិត សន្មតថាមិនផ្លាស់ប្តូរការងារ ដោយសារខ្វះខាតជំនាញសមរម្យ។ ស្ត្រី ត្រូវបានគេរកឃើញថា ពួកគេបានខិតខំប្រឹងប្រែងខ្លាំងជាងបុរស ក្នុងការប្តូរជំនាញ។

លទ្ធផលស្រាវជ្រាវបង្ហាញថា កញ្ចប់ជំនួយរបស់រដ្ឋាភិបាលសម្រាប់គ្រួសារមិនមានភាពគ្រប់គ្រាន់ ដោយមានតែគ្រួសារដែលរងផលប៉ះពាល់ ២៧% ប៉ុណ្ណោះ ទទួលបានជំនួយក្នុងឆ្នាំ២០២១ ហើយចំនួននេះបានកើនដល់ ៣១.៤% ក្នុងឆ្នាំ២០២២។ ទោះបីជាបន្ទុកនៃការថែទាំ និងការងារតាមផ្ទះធ្លាក់ចុះមិនសមាមាត្រលើស្ត្រីក៏ដោយ មានបុរសកាន់តែច្រើនទទួលបានការគាំទ្រតាំងនាមឱ្យគ្រួសាររបស់ពួកគេ។

បញ្ហាដែលគ្រួសារទាំងអស់ ជាពិសេសគ្រួសារដែលមានស្ត្រីជាមេគ្រួសារប្រឈមមុខគឺ បញ្ហា កង្វះទំនាក់ទំនងក្នុងការគាំទ្រតាមអ៊ីនធឺណិត និងភាពទន់ខ្សោយក្នុងការចូលប្រើប្រាស់ប្រព័ន្ធគាំពារសង្គម។



គ្រួសារដែលមានស្ត្រីជាមេគ្រួសារ មានបទពិសោធន៍ការស្តារឡើងវិញខ្សោយជាង គ្រួសារដែលមានបុរសជាមេគ្រួសារ។

បញ្ហានេះ អាចធ្វើឲ្យប្រសើរឡើងបានតាមរយៈការអភិវឌ្ឍទិន្នន័យមូលដ្ឋានប្រជាពលរដ្ឋឲ្យកាន់តែទូលំទូលាយ និងឲ្យមានការផ្តល់ដំបូន្មាននៅលើអ៊ីនធឺណិត រួមជាមួយនឹងកិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនជំនាញ និងសមត្ថភាពក្នុងការចូលប្រើប្រព័ន្ធគាំពារសង្គម។

## មេរៀនសំខាន់ៗបីសម្រាប់ថ្ងៃអនាគត

១ ជំនួយសង្គ្រោះបន្ទាន់ និងការផ្តល់សុខុមាលភាព ត្រូវតែបន្តផ្តល់ ទោះបីវិបត្តិជំងឺរាតត្បាតត្រូវបាន បញ្ចប់ក៏ដោយ។

២ អ្នកដែលត្រូវការជំនួយ ត្រូវតែអាចទទួលបានជំនួយទាំងនោះយ៉ាងងាយស្រួល។

៣ និយោជិត ជាពិសេសស្ត្រី ត្រូវការវគ្គបណ្តុះបណ្តាលជំនាញបន្ថែម។

Centre for Economic and Social Development (CESD)
IDRC · CRDI International Development Research Centre / Centre de recherches pour le développement international
Canada
CDRI Cambodia Development Resource Institute
CAF PHÂN TÍCH & DỰ BÁO
MORE INFORMATION



# តើជំងឺរាតត្បាតកូវីដ-១៩ បានប៉ះពាល់អ្វីខ្លះដល់អ្នកផលិតសម្លៀកបំពាក់របស់យើង?

ការស្រាវជ្រាវពីប្រទេស
កម្ពុជា មីយ៉ាន់ម៉ា និងវៀតណាម

# ស្ត្រីជាច្រើននៅប្រទេស កម្ពុជា មីយ៉ាន់ម៉ា និងវៀតណាម បាន ទទួលរងផលប៉ះពាល់យ៉ាងខ្លាំងពីការរាតត្បាតនៃជំងឺកូវីដ-១៩

## ទាំងនេះ ជាមេរៀនដែលត្រូវរៀនសូត្រ និងសម្រាប់រៀបចំផែនការអភិវឌ្ឍ

ក្នុងអំឡុងពេល និងក្រោយពេលនៃការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ ឧស្សាហកម្មកាត់ដេរនៅក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើន បានរងការរំខានយ៉ាងខ្លាំង ហើយបានបន្សល់នូវផលជះផ្សេងៗ ទៅលើសេដ្ឋកិច្ច និងសង្គមរហូតមកដល់សព្វថ្ងៃនេះ។ បន្ថែមពីលើផលប៉ះពាល់ដោយផ្ទាល់ពីការបិទខ្ទប់ ដែលបានកាត់បន្ថយការនាំចេញ ឧស្សាហកម្មកាត់ដេរ បានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារការពឹងផ្អែកយ៉ាងខ្លាំងលើការនាំចូលកំណាត់វត្ថុធាតុដើម និងគ្រឿងលំអបន្ថែមជាដើមពីបណ្ដាប្រទេសផ្សេងទៀត។

បើទោះបីជាការស្ដារឡើងវិញកំពុងតែងើបឡើងបន្តិចម្ដងៗ តែអាជីវកម្មមួយចំនួនបានបិទទ្វារ ហើយគ្រួសារមួយចំនួនធំបានជួបវិបត្តិហិរញ្ញវត្ថុ និងសង្គមយ៉ាងធ្ងន់ធ្ងរ។ បញ្ហាទាំងនេះ បានជះឥទ្ធិពល មកលើសុខភាពផ្លូវចិត្តខ្លាំងដែរ។

ជាមួយគ្នានេះដែរ ផលប៉ះពាល់អវិជ្ជមានធំៗមួយចំនួន បានធ្លាក់ទៅលើស្ត្រីធ្ងន់ជាងគេ។ នេះជាមេរៀនដែលត្រូវរៀនសូត្រ និងសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ចំពោះវិបត្តិស្រដៀងគ្នាដែលអាចកើតឡើងនាពេលអនាគត។

អ្នកស្រាវជ្រាវបានពិនិត្យមើលផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ-១៩ និងដំណើរការស្ដារឡើងវិញរបស់រដ្ឋាភិបាលយ៉ាងយកចិត្តទុកដាក់ ជាពិសេសទៅលើសារៈសំខាន់នៃបញ្ហាយេនឌ័រ ការផ្ដោតសំខាន់លើឧស្សាហកម្មកាត់ដេរ គឺជាផ្នែកមួយដ៏សំខាន់ក្នុងគម្រោងស្ដីពី «ផលប៉ះពាល់នៃជំងឺកូវីដ១៩ មកលើការអភិវឌ្ឍប្រកបដោយបរិយាបន្ន និងអភិបាលកិច្ច៖ ការវាយតម្លៃរហ័សក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម» ក្រោមជំនួយមូលនិធិពី មជ្ឈមណ្ឌលស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសកាណាដា។



ឧស្សាហកម្មកាត់ដេរ បានទទួលរងការរំខានយ៉ាងខ្លាំងក្នុងអំឡុងពេល និងក្រោយការមានជំងឺរាតត្បាត ដោយសារមានស្ត្រីកាន់តែច្រើនទទួលផលប៉ះពាល់ជាអវិជ្ជមាន។

## កម្ពុជា

ក្រុមអ្នកស្រាវជ្រាវនៃវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) នៅក្នុងខែមិថុនា ឆ្នាំ២០២១ បានធ្វើបទសម្ភាសន៍តាមទូរស័ព្ទជាមួយនិយោជិតចំនួន ២,០០០ នាក់ នៅក្នុងវិស័យកាត់ដេរ ស្បែកជើង និងសម្ភារៈសម្រាប់ធ្វើដំណើរ ដើម្បីធ្វើការវាយតម្លៃលើផលប៉ះពាល់ពីជំងឺរាតត្បាតលើសេដ្ឋកិច្ច សង្គម និងបញ្ហាផ្លូវចិត្ត។ ដើម្បីតាមដានលទ្ធផល បទសម្ភាសន៍តាមទូរស័ព្ទនេះ ត្រូវបានធ្វើម្ដងទៀតក្នុងរយៈពេលមួយឆ្នាំក្រោយមក។ លទ្ធផលនៃការស្រាវជ្រាវ បានបង្ហាញថា ការងើបឡើងវិញមានសន្ទុះខ្លាំង ទាំងក្នុងឧស្សាហកម្មកាត់ដេរ និងការរស់នៅរបស់និយោជិត។ ម្យ៉ាងទៀត ស្ត្រីទទួលបានអត្ថប្រយោជន៍ដូចគ្នានឹងបុរសដែរ។

> ”
> **ការបណ្ដុះបណ្ដាលជំនាញដឹកនាំដោយរដ្ឋាភិបាល មានសារៈសំខាន់ណាស់ក្នុងការធ្វើឲ្យប្រសើរឡើងនូវជម្រើសរបស់និយោជិតនៅក្នុងរយៈពេលវែង។**

ទោះជាយ៉ាងនេះក្ដី ស្ត្រីបានរងផលប៉ះពាល់ច្រើនជាងគេ ពីការបិទរោងចក្រកាត់ដេរ ស្បែកជើង និងសម្ភារៈសម្រាប់ធ្វើដំណើរ ដោយសារតែរោងចក្រទាំងនេះមាននិយោជិតភាគច្រើនជាស្ត្រី។ ទោះបីជាប្រាក់ចំណូលរបស់និយោជិតបានកើនឡើងវិញក៏ដោយ ប៉ុន្តែភាពតានតឹងថ្មីៗនៅតែមាន ដូចជាការកើនឡើងនៃតម្លៃអាហារ និងប្រេងសាំងជាដើម។

ក្រុមការងារ CDRI បានសន្និដ្ឋានថា ស្ត្រីនៅក្នុងវិស័យនេះ នៅតែងាយរងគ្រោះជាងបុរសដោយសារតែផលវិបាករយៈពេលវែងនៃជំងឺកូវីដ-១៩។ ក្រុមអ្នកស្រាវជ្រាវ បានស្នើឱ្យមានវិធានការផ្អែកលើយេនឌ័រ ដើម្បីធ្វើយ៉ាងណាជួយពួកគេឲ្យបន្តការងារទៅមុខ និងអាចដោះស្រាយវិបត្តិស្រដៀងគ្នានេះនាពេលអនាគត។ វិធានការទាំងនេះ រួមមានសកម្មភាពដឹកនាំដោយរដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រសើរឡើងនូវចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជំនាញឌីជីថល បន្ថែមលើការបណ្ដុះបណ្ដាលដើម្បីធ្វើការងារជាក់លាក់ណាមួយរបស់ពួកគេ។



ឧស្សាហកម្មកាត់ដេរ បានទទួលរងការរំខានយ៉ាងខ្លាំងក្នុងអំឡុងពេល និងក្រោយការមានជំងឺរាតត្បាត ដោយសារមានស្ត្រីកាន់តែច្រើនទទួលផលប៉ះពាល់ជាអវិជ្ជមាន។

ការបណ្ដុះបណ្ដាលជំនាញបន្ថែម និងការបណ្ដុះបណ្ដាលជំនាញឡើងវិញ នឹងដើរតួយ៉ាងសំខាន់ក្នុងការធ្វើឲ្យប្រសើរឡើងនូវជម្រើសរបស់និយោជិត ជាពិសេសការងារក្នុងហាងកែសម្ផស្ស និងកាត់ដេរ។ ជម្រើសការងារទាំងនេះ សុទ្ធសឹងតែជាចំណង់ចំណូលចិត្តរបស់ស្ត្រី ដែលប្រហែលជាត្រូវបានជះឥទ្ធិពលមកពីវប្បធម៌ ប្រពៃណី និងឧបសគ្គក្នុងការរកការងារផ្សេងទៀត។ ក្រុមអ្នកស្រាវជ្រាវអះអាងថា ការគាំទ្រទាំងនេះ មានភាពចាំបាច់ដើម្បីធានាចំពោះនិយោជិត ថាពួកគេនឹងមិនបាត់បង់ប្រាក់ឈ្នួលដោយសារការយកពេលវេលាទៅចូលរួមវគ្គបណ្ដុះបណ្ដាលជំនាញបន្ថែមនោះឡើយ។

## មីយ៉ាន់ម៉ា

ការសិក្សាមួយធ្វើឡើងដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម (CESD) នៃប្រទេស មីយ៉ាន់ម៉ា បានរកឃើញថា ជំងឺកូវីដ-១៩ បានគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់និរន្តរភាពនៃឧស្សាហកម្មកាត់ដេរ និងវាយនភណ្ឌរបស់ប្រទេស។ វាបណ្ដាលឱ្យមានការបិទរោងចក្រ និងអាជីវកម្មមួយចំនួននៅក្នុងអនុវិស័យវាយនភណ្ឌ ដែលពិបាកក្នុងការស្ដារឡើងវិញនៅក្នុងរយៈខ្លី។

ក្រុមអ្នកស្រាវជ្រាវបានរកឃើញថា មានមនុស្សជាច្រើនដែលធ្វើការក្នុងឧស្សាហកម្មនេះបានបាត់បង់ការងារធ្វើ។ ក្រុមហ៊ុនតូចៗទទួលរងគ្រោះយ៉ាងខ្លាំង បើប្រៀបធៀបនឹងរោងចក្រធំៗ។

យុទ្ធសាស្ត្រឆ្លើយតប ដែលអាជីវកម្មសេសសល់ក្នុងឧស្សាហកម្មកាត់ដេរពេញនិយមប្រើប្រាស់ជាងគេនោះគឺ ការទប់ស្កាត់ការដំឡើងប្រាក់ឈ្នួល ដើម្បីឲ្យតម្លៃពលកម្មរបស់ខ្លួនមានភាពប្រកួតប្រជែងចំពោះក្រុមហ៊ុនបញ្ជាទិញ ដែលកំពុងជួបនឹងវិបត្តិ។



និយោជិតជាស្ត្រីមាន ៨៦% នៃកម្លាំងពលកម្មក្នុងឧស្សាហកម្មកាត់ដេរ។

និយោជិតជាស្ត្រីមាន៨៦%នៃកម្លាំងពលកម្មក្នុងឧស្សាហកម្មកាត់ដេរ។ នេះបើធៀបទៅនឹងវិស័យទាំងអស់ទូទាំងប្រទេសដែលនិយោជិតជាស្ត្រីមានតែជាង ៥០% ប៉ុណ្ណោះ។ អ្នកដែលរងផលប៉ះពាល់ដោយការបិទរោងចក្រ ទំនងជាមិនសូវមានលទ្ធភាព ឬអាចស្វែងរកការងារថ្មីក្នុងវិស័យផ្សេងក្រៅពីឧស្សាហកម្មកាត់ដេរនោះទេ។ ប្រការនេះ បានធ្វើឱ្យពួកគេមានភាពងាយរងគ្រោះជាងនិយោជិតជាបុរស ដោយសារបុរសមានឱកាសការងារច្រើនជាងស្ត្រីក្នុងវិស័យកសិកម្ម និងមុខរបរផ្សេងទៀតដែលត្រូវបានចាត់ទុកថាជាការងារបុរស។ ដោយសារកង្វះឱកាសការងារជំនួសនេះហើយ ទើបនិយោជិតជាស្ត្រីទាំងនេះមានអំណាចចរចាតិចតួចជាមួយនិយោជកផងដែរ។

> ”
> **ស្ត្រី មិនមានលទ្ធភាពក្នុងការស្វែងរកការងារថ្មីក្រៅពីឧស្សាហកម្មកាត់ដេរទេ។នេះបើប្រៀបធៀបទៅនឹងបុរសដែលមានឱកាសការងារច្រើនជាង។**

ស្ត្រី ក៏បានប្រឈមមុខនឹងបញ្ហាសង្គមច្រើនជាងបុរសផងដែរ រួមទាំងផ្នែកថែទាំសុខភាព និងរចនាសម្ព័ន្ធគាំទ្រសង្គម។ ឧទាហរណ៍៖ ការផ្ដល់សេវាសុខភាពបន្តពូជ និងការសម្រាលកូន ត្រូវបាន ផ្ដល់ជូននៅក្នុងកំឡុងពេលជំងឺរាតត្បាតបានថមថយ។

ដើម្បីទទួលបានលទ្ធផលស្រាវជ្រាវទាំងនេះ ក្រុមអ្នកស្រាវជ្រាវបានប្រមូលទិន្នន័យពីអ្នកចូលរួមចំនួន ៦១០ នាក់តាមរយៈការរួមបញ្ចូលគ្នានៃការស្ទង់មតិតាមទូរស័ព្ទ និងការសម្ភាសន៍ជាក្រុមនៅចន្លោះខែកក្កដា ឆ្នាំ២០២០ ដល់ខែមករា ឆ្នាំ២០២១។